PARTNER PUBLICATION



# ឆ្ពោះទៅវេទិកាពហុភាគីពាក់ព័ន្ធនៅក្នុងអាងទន្លេមេគង្គ

ដៃគូដែនទឹករួមគ្នា (SWP) នៃកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) ក្រោមការរៀបចំរបស់ SIWIបានធ្វើការស្ទង់មតិនិងធ្វើការវិភាគយ៉ាងទូលាយមួយទៅលើតួអង្គមិនមែនរដ្ឋាភិបាលដែលមានការពាក់ព័ន្ធ ដើម្បីកំណត់អំពីឱកាសនិងចំណុចចាប់ផ្តើមនានា ដើម្បីកែលម្អការចូលរួមរវាងភាគីពាក់ព័ន្ធដែលជារដ្ឋាភិបាលនិងមិនមែនរដ្ឋាភិបាលនៅក្នុងអាងទន្លេមេគង្គ។ លទ្ធផលបង្ហាញថាមានការចាប់អារម្មណ៍យ៉ាងច្រើនក្រៃលែង ក្នុងការបង្កើតវេទិកាពហុភាគីពាក់ព័ន្ធមួយ (MSP) ដែលនឹងបំពេញបន្ថែមទៅលើស្ថាប័ននិងបណ្តាញដែលមានស្រាប់ ដើម្បីជំរុញដោយផ្ទាល់ចំពោះដំណើរការអន្តររដ្ឋាភិបាលក្នុងតំបន់ចំពោះការចូលរួមរបស់ភាគីពាក់ព័ន្ធ និងចំពោះកិច្ចសហប្រតិបត្តិការ ថ្នាក់តំបន់។

## ការប្រឈម

ការប្រឈមដ៏ស្មុគ្រស្មាញមួយទៅលើ ការងារអភិបាលកិច្ច ការអភិវឌ្ឍន៍និងការគ្រប់គ្រងទន្លេមេគង្គដែលជាអាងទន្លេឆ្លងដែនដែលមានប្រជាជនច្រើនបំផុតនិងដែលធំបំផុតមួយនៅក្នុងពិភពលោកនេះ។ ជារឿយៗមានការប្រកួតប្រជែងរវាងផលប្រយោជន៍ស្របច្បាប់រវាងគ្នាទៅវិញទៅមក ទាក់ទងនឹងការអភិវឌ្ឍន៍ដែលទាមទារឲ្យមានតុល្យភាពរវាងផលប្រយោជន៍រួមគ្នា និងអាទិភាពពីប្រទេសនិងតួអង្គផ្សេងៗគ្នារវាង ប្រទេសទាំងប្រាំមួយដែលមានទន្លេមេគង្គ (កម្ពុជា ចិន ឡាវ មីយ៉ាន់ម៉ា ថៃ វៀតណាម)។

ដើម្បីគ្រប់គ្រងទៅលើសេចក្តីប្រាថ្នានិងតម្រូវការដ៏ច្រើនសន្ធឹកសន្ធាប់របស់ប្រទេសនិមួយៗ វេទិកាអន្តររដ្ឋាភិបាលជាច្រើនត្រូវបានបង្កើតឡើងដើម្បីជួយប្រទេសទាំងឡាយធ្វើយ៉ាងណាឲ្យផែនការអភិវឌ្ឍន៍របស់ខ្លួន មានការរីកចម្រើនជាធ្លុងមួយ។ ក៏ប៉ុន្តែ ទោះបីជាមានការសន្ទនាជាទៀងទាត់រវាងប្រទេសនានា នៅកម្រិតការទូតខ្ពស់ក៏ដោយ ក៏ការចូលរួមជាមួយតួអង្គមិនមែនរដ្ឋាភិបាលឲ្យបានទូលំទូលាយនៅមិនទាន់គ្រប់គ្រាន់នៅឡើយទេ។

ក្នុងន័យសុទិដ្ឋិនិយម កង្វះខាតការចូលរួមជាផ្លូវការនិងមានតម្លាភាពជាមួយតួអង្គមិនមែនរដ្ឋាភិបាល គឺជាឱកាសដែលវេទិកាអន្តររដ្ឋាភិបាលបច្ចុប្បន្នខកខានមិនបានទទួល ដែលអាចជាការទាញយកប្រយោជន៍ដ៏ប្រសើរមួយពីអង្គការនានាដែលមានសមត្ថភាពខ្ពស់និងមានការផ្តោតការយកចិត្តទុកដាក់នៅថ្នាក់តំបន់ ដើម្បីធ្វើឲ្យគ្រប់គ្រងនិងការអភិវឌ្ឍន៍ធនធានទឹកបានឡើងដល់កម្រិតខ្ពស់បំផុត។ ក្នុងន័យទុទិដ្ឋិនិយម អវត្តមានការចូលរួមដោយស្មោះត្រង់អាចបង្កើនភាពតានតឹងនៅក្នុងអាងទន្លេ នៅកម្រិតមហាជននិងកម្រិតមូលដ្ឋានដោយទុកឲ្យប្រជាជនដែលងាយរងគ្រោះ កាន់តែមានភាពមិនច្បាស់លាស់ថែមទៀត អំពីបញ្ហាសន្តិសុខស្បៀង ទឹក និង ថាមពលសម្រាប់អនាគតរបស់ពួកគេ។

ការបង្កើតវេទិកាពហុភាគីពាក់ព័ន្ធ សម្រាប់អង្គការមិនមែនរដ្ឋរដ្ឋាភិបាល នឹងផ្តល់ប្រយោជន៍ដល់រដ្ឋាភិបាលនិងអន្តររដ្ឋាភិបាលនៃតំបន់មេគង្គ និង តាមរយៈការផ្តល់ដល់ពួកគេ៖

- មានការចូលរួមកាន់តែមាននិរន្តរភាព និងការផ្សព្វផ្សាយជាប្រព័ន្ធជាលក្ខណៈស្ថាប័ន និងជាទៀងទាត់ ដល់ភាគីពាក់ព័ន្ធនានា
- ចែករំលែកផែនការជាមួយភាគីពាក់ព័ន្ធនិងអ្នកស្រាវជ្រាវព្រមទាំងទទួលយោបល់ត្រឡប់ ទៅលើគម្រោងជាក់លាក់នានា និងដើម្បីចែករំលែកនូវយោបល់ត្រឡប់ទាំងនេះជាមួយអ្នកអភិវឌ្ឍន៍ និងតួអង្គពាក់ព័ន្ធផ្សេងទៀតដែលពីមុន មិនសូវបានធ្វើដោយទៀងទាត់។

## វិធីសាស្ត្រ

ក្នុងចំណោមអង្គការថ្នាក់តំបន់ប្រហែល៣៩ បានឆ្លើយតបការស្ទង់មតិតាមប្រព័ន្ធអេឡិចត្រូនិច* ដោយក្នុងនោះ អង្គការចំនួន២៨ក៏បានចូលរួមនៅក្នុងការសម្ភាសបន្ត ដោយទាក់ទងនឹង៖

- អាណត្តិ វិសាលភាពមុខងារ និងសមត្ថភាពរបស់អង្គការនិមួយៗ ពាក់ព័ន្ធនឹងបញ្ហានានាអំពីអភិបាលកិច្ចទឹកទន្លេមេគង្គ និងកិច្ចសហប្រតិបត្តិការក្នុងអាងទន្លេមេគង្គ
- លក្ខណៈនៃទំនាក់ទំនងនិងអន្តរកម្មរបស់អង្គការនិមួយៗ ជាមួយក្រុមភាគីពាក់ព័ន្ធផ្សេងៗនៅក្នុងអាងទន្លេ
- ទស្សនៈរបស់អង្គការទាំងនោះ ទៅលើការផ្តួចផ្តើម ការបង្កើត និងគោលបំណងនៃវេទិកាពហុភាគីពាក់ព័ន្ធក្នុងអាងទន្លេមេគង្គ។

* ការស្ទង់មតិនេះ ត្រូវបានផ្ញើទៅតួអង្គមិនមែនរដ្ឋាភិបាលចំនួន១០០ នៅថ្នាក់តំបន់។ លក្ខណៈវិនិច្ឆ័យ គឺថា ពួកគេគឺជាអង្គការដែលនៅក្នុងបណ្តាញឬអង្គការ ឬដែលបានចូលរួមនៅក្នុងបណ្តាញឬអង្គការដែលប្រតិបត្តិការរវាងប្រទេសពីរឬច្រើន នៅក្នុងអាងទន្លេមេគង្គ រួមមានដូចជា អង្គការមិនមែនរដ្ឋាភិបាល / បណ្តាញ/អង្គការសង្គមស៊ីវិល សមាគមនឬវេទិកាធុរកិច្ចថ្នាក់តំបន់ និងសាកលវិទ្យាល័យ អង្គការស្រាវជ្រាវ បណ្តាញ ក្រុមអ្នកយុទ្ធសាស្ត្រ ឬកម្មវិធីនានានៅថ្នាក់ តំបន់។




រូបទី១៖ អ្នកឆ្លើយតបក្នុងការស្ទង់មតិដោយប្រទេសតាមដងទន្លេ




រូបទី២៖ អ្នកឆ្លើយតបក្នុងការស្ទង់មតិដោយតំណាងដែលមានកំណត់ឋានៈស្របច្បាប់ដោយខ្លួនឯង

លទ្ធផលនៃការស្ទង់មតិនេះ ត្រូវបានចែករំលែកជាមួយអ្នកឆ្លើយតបមួយចំនួននៅក្នុងកិច្ចប្រជុំមួយនៅទីក្រុងបាងកក ក្នុងខែវិច្ឆិកា ឆ្នាំ២០១៦ ដែលអ្នកចូលរួមបានពិភាក្សាអំពីទម្រង់និងមុខងារជាសក្ដានុពលរបស់វេទិកាពហុភាគីពាក់ព័ន្ធ ដែលបានស្នើឡើងនេះ។ បន្ទាប់មក គំនិតនិងសំណួរនានាដែលលេចឡើងពីការពិភាក្សានោះ ត្រូវបានពន្យល់លម្អិតជាមួយនឹងអ្នកតំណាងមកពីគណៈកម្មាធិការទន្លេមេគង្គ និងកិច្ចសហប្រតិបត្តិមេគង្គឡានសាង នៅក្នុងកិច្ចប្រជុំផ្សេងដោយឡែក។

## លទ្ធផល

ត្រូវការមានការចូលរួមសម្រាប់ភាគីពាក់ព័ន្ធទូលំទូលាយនៅក្នុងតំបន់មេគង្គ| ថ្វីត្បិតតែមានគម្រោងផ្ដួចផ្ដើមសំខាន់មួយចំនួនទាក់ទងនឹងអភិបាលកិច្ចទឹកថ្នាក់តំបន់ក៏ដោយ ក៏នៅមានការរិះគន់ជុំវិញបញ្ហាកង្វះខាតការបញ្ចូលតួអង្គមិនមែនរដ្ឋ និងទៅលើវិធីសាស្ត្រចូលរួមនិងប្រាស្រ័យទាក់ទង ដែលជារឿយៗមិនទាន់មានលក្ខណៈគ្រប់គ្រាន់និងមានតម្លាភាពតែផ្នែកខ្លះៗនោះ។

ចំណុចនេះជាការមិនបានយកចិត្តទុកដាក់ដល់ធាតុចូលរបស់ប្រជាសហគមន៍រាប់សិបលាននាក់ ដែលទទួលរងផលប៉ះពាល់ដោយសារការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធទឹក និងជាការរឹតត្បិតដល់ការយល់ដឹងអំពីគម្រោងអភិវឌ្ឍន៍។

បន្ថែមពីលើនេះ មានអង្គការជាច្រើននៅក្នុងតំបន់ដែលមានបទពិសោធន៍និងជំនាញដ៏មានតម្លៃនៅក្នុងវិស័យគ្រប់គ្រងធនធានធម្មជាតិ ប៉ុន្តែ ពួកគេមានឱកាសតិចតួចណាស់ ក្នុងការរួមចំណែកជាពិសេសនៅកម្រិតតំបន់ តាមលក្ខណៈផ្លូវការឬឲ្យមានលក្ខណៈរួមគ្នានៅមានកម្រិត។

ស្ថាប័នអភិបាលកិច្ចទឹកថ្នាក់តំបន់ ដែលមានស្រាប់៖
1. គណៈកម្មាធិការទន្លេមេគង្គ
2. មហាអនុតំបន់ទន្លេមេគង្គ
3. យន្តការសហប្រតិបត្តិការឡានសាង-មេគង្គ

អង្គការថ្នាក់តំបន់មានការគាំទ្រខ្លាំងចំពោះគំនិតអំពីវេទិកាពហុភាគីពាក់ព័ន្ធ|ការធ្វើវិភាគភាគីពាក់ព័ន្ធបានរកឃើញថា មានការគាំទ្រវិជ្ជមានខ្លាំងចំពោះការមានវេទិការពហុភាគីពាក់ព័ន្ធនេះ។ អង្គការចំនួន ៣៤ (នៃ ៣៩) បានលើកឡើងថាពួកគេមើលឃើញគុណតម្លៃក្នុងការបង្កើតវេទិកាពហុភាគីពាក់ព័ន្ធដែលមាននៅថ្នាក់តំបន់ ដែលរួមបញ្ចូលប្រទេសទាំងប្រាំមួយ ព្រមទាំងតភ្ជាប់និងចូលរួមគ្នាដោយផ្ទាល់នៅក្នុងដំណើរការអន្តររដ្ឋាភិបាលថ្នាក់តំបន់។

ដែលរួមបញ្ចូលប្រទេសទាំងប្រាំមួយ ព្រមទាំងតភ្ជាប់និងចូលរួមគ្នាដោយផ្ទាល់នៅក្នុងដំណើរការអន្តររដ្ឋាភិបាលថ្នាក់តំបន់។ អ្នកឆ្លើយតបចំនួនប្រាំទៀត ក៏មានគាំទ្រដែរ ប៉ុន្តែ ពួកគេបានកត់សម្គាល់ថា ពួកគេចង់ឲ្យបន្តពីវេទិកានានាដែលមានស្រាប់នាពេលបច្ចុប្បន្ននេះ។

តើវេទិកាពហុភាគីពាក់ព័ន្ធត្រូវមានទំនាក់ទំនងអ្វីទៅនឹងគណៈកម្មាធិការទន្លេមេគង្គ | អ្នកឆ្លើយតបមើលឃើញថា គណៈកម្មាធិការទន្លេមេគង្គ ជាគោលដៅសំខាន់សម្រាប់ការចូលរួម និងមើលឃើញថាវេទិកាពហុភាគីពាក់ព័ន្ធដែលស្នើឡើងនេះជាការផ្ដល់ឲ្យ គណៈកម្មាធិការទន្លេមេគង្គជាចំនុចចាប់ផ្ដើមដែលច្បាស់លាស់មួយសម្រាប់ការចូលរួមរបស់ភាគីពាក់ព័ន្ធនៅក្នុងតំបន់។ ក៏ប៉ុន្តែ ក្ដីបារម្ភសំខាន់ៗ រួមមានដូចជាថា គណៈកម្មាធិការទន្លេមេគង្គនៅមានកម្រិតក្នុងជះឥទ្ធិពលទៅលើរដ្ឋាភិបាលប្រទេសនិមួយៗ ក្នុងការចែករំលែកព័ត៌មាន និងផ្ដោតតែទៅលើប្រទេសក្នុងអាងទន្លេមេគង្គក្រោម ហើយមានការចូលរួមតិចតួចពីប្រទេសចិន និងប្រទេសមីយ៉ាន់ម៉ា។

ពួកគេបានសង្កត់ធ្ងន់ថា វេទិកានេះ មិនគួរភ្ជាប់ទៅតែជាមួយគណៈកម្មាធិការ ទន្លេមេគង្គនោះទេ ប៉ុន្តែ ត្រូវរក្សានូវឯករាជ្យភាពរបស់ខ្លួន។ វេទិកានេះ គួរចូលរួមនៅកម្រិតតំបន់ ដែលមិនមែនត្រឹមតែជាមួយគណៈកម្មាធិការទន្លេមេគង្គទេ គឺគួរតែចូលរួមជាមួយយន្តការសហប្រតិបត្តិការឡានសាង-មេគង្គ មហាអនុតំបន់ទន្លេមេគង្គ និងអាស៊ាន តាមការសមស្រប។

បញ្ហាអាទិភាពសម្រាប់អង្គការថ្នាក់តំបន់ | អ្នកឆ្លើយតបត្រូវបានស្នើឲ្យជ្រើសរើសបញ្ហាអាងទន្លេមេគង្គជាអាទិភាពបំផុតសម្រាប់អង្គការរបស់ពួកគេ ចេញពីបញ្ជីដែលមានរៀបរាប់អំពីជម្រើសដែលអាចកើតឡើង។ បញ្ជីនេះ កំណត់បញ្ហាចេញពីតម្រូវការនិងបញ្ហាប្រឈមរបស់អាង ដែលមានរៀបរាប់នៅក្នុងផែនការយុទ្ធសាស្ត្រគណៈកម្មាធិការទន្លេមេគង្គ ២០១៦-២០២០, យុទ្ធសាស្ត្រអភិវឌ្ឍន៍អាង ២០១៦-២០២០, កិច្ចព្រមព្រៀងឆ្នាំ១៩៩៥ និងយោបល់អ្នកជំនាញ។ អ្នកឆ្លើយតប ក៏មានជម្រើសក្នុងការសរសេរបញ្ហា"ផ្សេង"ដែរ ដោយក្នុងនោះអ្នកឆ្លើយតបជាច្រើន បានឆ្លើយលើសពីបីបញ្ហា។

បញ្ហាអាទិភាពបំផុតចំនួន៥ សម្រាប់អង្គការថ្នាក់តំបន់៖
1. ការអភិវឌ្ឍន៍ទំនប់វារីអគ្គីសនី
2. អភិបាលកិច្ចទឹកឆ្លងដែន
3. បម្រែបម្រួលអាកាសធាតុ
4. ការថយចុះនៃគុណភាពបរិស្ថាន
5. ថាមពល



រូបទី៣៖ អាទិភាពនៃបញ្ហាក្នុងអាងទន្លេមេគង្គ ដែលជ្រើសរើសដោយអង្គការថ្នាក់តំបន់ទាំង៣៩

## អនុសាសន៍

លទ្ធផលនៃការស្ទង់មតិនិងការពិភាក្សាជាមួយភាគីពាក់ព័ន្ធ នៅក្នុងកិច្ចប្រជុំនៅទីក្រុងបាងកក កាលពីខែវិច្ឆិកា ឆ្នាំ២០១៦ បង្ហាញថា វេទិកាពហុភាគីពាក់ព័ន្ធអាងទន្លេមេគង្គ អាចអនុវត្តតាមអាទិភាពនិងរចនាសម្ព័ន្ធខាងក្រោម៖

អាទិភាព
- កែលម្អការសន្ទនា ការងារបណ្តាញ និងកិច្ចសហប្រតិបត្តិការ
- សម្របសម្រួលសកម្មភាពនិងអន្តរាគមន៍
- ការកសាងសមត្ថភាព
- ផ្តល់វិសាលភាពថ្នាក់តំបន់ ទៅក្នុងការពិគ្រោះយោបល់ថ្នាក់ជាតិ
- តំណាងទស្សនៈយោបល់នានាមកពីគ្រប់ប្រទេស ក្នុងចក្ខុវិស័យរួមគ្នាមួយ
- លើកកម្ពស់ផលប្រយោជន៍រួមគ្នាពាសពេញអាងទន្លេ
- បញ្ចុះបញ្ចូលទៅលើយុទ្ធសាស្ត្រម្ចាស់ជំនួយ
- សម្រួលការរៀនសូត្រនិងការចែករំលែកព័ត៌មាន
- បញ្ចុះបញ្ចូលទៅលើវេទិកាផ្លូវការ (គណៈកម្មាធិការទន្លេមេគង្គ និងកិច្ចសហប្រតិបត្តិការឡានស័ាង-មេគង្គ)
- ការផ្សព្វផ្សាយចំណេះដឹង ដើម្បីផ្សារភ្ជាប់រវាងគោលនយោបាយ និងវិទ្យាសាស្ត្រ
- បង្កើតវេទិកាអព្យាក្រឹត្យ
- បង្រួបបង្រួមរបៀបវារៈនៃការអភិរក្សនិងការអភិវឌ្ឍន៍

បង្កើត
- លេខាធិការដ្ឋានតូចមួយ ស្ថិតក្នុងទីតាំងរបស់នីតិបុគ្គលដែលមានស្រាប់ណាមួយ
- មុខងារផ្សព្វផ្សាយទូលំទូលាយ
- ឯករាជ្យ អព្យាក្រឹត្យ មិនលម្អៀង
- ភាពស្របច្បាប់រឹងមាំនិងមានទំនាក់ទំនងល្អជាមួយភាគីពាក់ព័ន្ធនានា ទាំងតួអង្គមិនមែនរដ្ឋនិងរដ្ឋាភិបាលផ្លូវការ

ស្ថាប័នដែលអាចយកជាទីតាំងបាន អាចជា
- សាកលវិទ្យាល័យ ឬ សមាគមសាកលវិទ្យាល័យ
- SIWI, IUCN, WWF, CGIAR/WLE, SUMERNET/SEI, Save the Mekong, VRN, Save the Salween

## ជំហានបន្ទាប់

របាយការណ៍នេះ នឹងបកប្រែជាភាសានៃប្រទេសនៅតាមដងទន្លេមេគង្គ និងផ្សព្វផ្សាយសម្រាប់ពិភាក្សាបន្ថែមជាមួយភាគីពាក់ព័ន្ធសំខាន់ៗ។ ក្រុមជនបង្គោលបណ្តោះអាសន្នមួយ ត្រូវបានបង្កើតឡើងហើយ (ដោយមានតំណាងមកពី SEI, SIWI, IUCN និង Oxfam)។ ក្រុមនេះនឹងទទួលខុសត្រូវ៖

1. បង្កើតទស្សនៈទានមួយ សម្រាប់ការបង្កើតវេទិកាពហុភាគីពាក់ព័ន្ធសម្រាប់ទន្លេមេគង្គ
2. ស្វែងរកការចូលរួមនិងការទទួលយកពីប្រទេសតាមទន្លេមេគង្គ
3. ការចូលរួមពីម្ចាស់ជំនួយ
4. កំណត់ឲ្យបានស្ថាប័នមួយដែលអាចជំរុញការបង្កើតវេទិកាពហុភាគីពាក់ព័ន្ធនេះ

## អំពីការបោះពុម្ពផ្សាយនេះ

ដៃគូដែនទឹករួមគ្នា (SWP) ក្រោមការរៀបចំរបស់ SIWI បានធ្វើការស្ទង់មតិ និងធ្វើការវិភាគយ៉ាងទូលាយមួយទៅលើតួអង្គមិនមែនរដ្ឋាភិបាលដែលមានការពាក់ព័ន្ធ ដើម្បីកំណត់អំពីឱកាសនិងចំនុចចាប់ផ្តើមនានា ដើម្បីកែលម្អការចូលរួមរវាងភាគីពាក់ព័ន្ធផ្លូវការនិងមិនផ្លូវការ នៅក្នុងអាងទន្លេមេគង្គ។ លទ្ធផល បង្ហាញថាមានការចាប់អារម្មណ៍យ៉ាងច្រើនក្រៃលែង ក្នុងការបង្កើតវេទិកាពហុភាគីពាក់ព័ន្ធមួយ ដែលនឹងបំពេញបន្ថែមទៅលើស្ថាប័ននិងបណ្តាញដែលមានស្រាប់ ដើម្បីជំរុញដោយផ្ទាល់ចំពោះដំណើរការអន្តររដ្ឋាភិបាលក្នុងតំបន់ ការចូលរួមរបស់ភាគីពាក់ព័ន្ធ និងកិច្ចសហប្រតិបត្តិការថ្នាក់តំបន់។

ឯកសារនេះ ត្រូវបានបោះពុម្ពផ្សាយក្រោមកិច្ចប្រឹងប្រែងរួមគ្នាដោយ SIWI និង Oxfam នៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៧។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង

SIWI - kerry.schneider@siwi.org
Oxfam - paulinetm@oxfam.org.au

## អ្នកនិពន្ធ

គម្រោងស្រាវជ្រាវនេះ រួមចំណែកដោយអ្នកជំនាញ SIWI Klomjit Chandrapanya, Dr Marian Neal (Patrick), Kerry Schneider, Maria Vink និង Elizabeth Yaari រួមជាមួយដៃគូ Stew Motta, កម្មវិធីស្តីពីទឹក ដី និងប្រព័ន្ធអេកូឡូស៊ី (WLE) របស់មហាទន្លេមេគង្គនៃ CGIAR និង Dr Nora Van Cauwenberg, UNESCO-IHE.

ការសិក្សាស្រាវជ្រាវនេះ ត្រូវបានផ្តល់ហិរញ្ញប្បទានដោយអង្គការអុកស្វាម ជាផ្នែកមួយនៃ Oxfam's Inclusion Project និងកម្មវិធីអភិបាលកិច្ចទឹកថ្នាក់តំបន់ទន្លេមេគង្គ ដែលកសាងការចូលរួមរបស់អង្គការសង្គមស៊ីវិលនៅក្នុងវិស័យអភិបាលកិច្ចទឹក តាមរយៈការកសាងសមត្ថភាពនិងការសន្ទនាគោលនយោបាយ។

OXFAM

Stockholm International Water Institute
Box 101 87 | SE-100 55, Stockholm, Sweden
Visiting Address: Linnégatan 87A
www.siwi.org

UNDP Empowered lives. Resilient nations.

WATER GOVERNANCE FACILITY

SIWI